# ប្រកាសលេខ ២៦៨

# ស្ដីពីការផ្ដល់វិញ្ញាប

# នប័ត្រអនុវត្តច្បាប់

# ស្ដីពីការងារចំពោះ

# សហគ្រាស គ្រឹះស្ថាន

00037

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
លេខ ១៧៦៨.សកបយ.

ភ្នំពេញ, ថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ ២០០០

# ប្រកាស
## ស្តីពី
## ការផ្តល់វិញ្ញាបនប័ត្រអនុវត្តច្បាប់ស្តីពីការងារចំពោះសហគ្រាស គ្រឹះស្ថាន

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/ ០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## សម្រេច

ប្រការ១: រៀងរាល់ដំណាច់ឆ្នាំនីមួយៗ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នឹងចេញប្រកាសសំរេចអំពី ការផ្តល់វិញ្ញាបនប័ត្រអនុវត្តច្បាប់ស្តីពីការងារចំពោះសហគ្រាស - គ្រឹះស្ថានទាំងឡាយ ដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារ ដែលសហគ្រាស គ្រឹះស្ថានទាំងនោះបានខិតខំអនុវត្តច្បាប់ស្តីពីការងារបានល្អប្រសើរ ។

ប្រការ២: លក្ខណៈវិនិច្ឆ័យសំរាប់ការពិនិត្យ និងសំរេចផ្តល់វិញ្ញាបនប័ត្រនោះមានដូចតទៅ :

-ការអនុវត្តនីតិវិធីលក្ខខណ្ឌការងារបានត្រឹមត្រូវ តាមការកំណត់ជាធរមាន អំពីថិរវេលាធ្វើការ ប្រាក់ឈ្នួល ការឈប់សំរាក ។ល។ ឬបានល្អប្រសើរជាង ។

-ទំនាក់ទំនងវិជ្ជាជីវៈល្អ រវាងនិយោជក និងតំណាងកម្មករនិយោជិត និងការអនុវត្តន៍សេរីភាពសហជីពបានល្អ ។

-ការអនុវត្តន៍វិធានអនាម័យ និងសន្តិសុខការងារបានល្អ ។

-ការបំពេញបែបបទសហគ្រាសបានល្អត្រឹមត្រូវ ។

ប្រការ៣: គណៈកម្មការមួយរបស់ក្រសួងដែលមាន អគ្គនាយកការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឬតំណាងជាប្រធាន ត្រូវពិនិត្យលក្ខណៈវិនិច្ឆ័យទាំងនេះអោយបានហ្មត់ចត់និងត្រឹមត្រូវ ដោយផ្អែកតាមរបាយការណ៍អធិការកិច្ចការងារ របស់នាយកដ្ឋានជំនាញ និងមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុងទាំងឡាយរបស់ក្រសួង ឬសំណើរបស់សហគ្រាសគ្រឹះស្ថាន ដើម្បីស្នើសុំសេចក្តីសំរេចរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

ប្រការ៤: ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទានឹងចេញផ្សាយជាសាធារណៈ នូវបញ្ជីរាយឈ្មោះសហគ្រាស គ្រឹះស្ថាន ដែលបានទទួលវិញ្ញាបនប័ត្រនេះ ។

ប្រការ៥: ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**អ៊ិត សំហេង**

**ចម្លងជូន**

-ខុទ្ទកាល័យព្រះមហាក្សត្រ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា ខេត្ត-ក្រុង "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-សមាគមនិយោជក "ដើម្បីជ្រាប"
-សហព័ន្ធសហជីព "ដើម្បីជ្រាប"
-គ្រប់សារព័ត៌មានវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច
-កាលប្បវត្តិ និងឯកសារ